ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ........................................................

# សុន្ទរកថា
## ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងឱកាសបើកសន្និបាតបូកសរុបលទ្ធផលការងារឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១៥ របស់ធនាគារជាតិនៃកម្ពុជា

រាជធានីភ្នំពេញ ថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៥

សូមគោរព :

- លោក Hervé DALLERAC ជំនាញការទូទៅប្រចាំធនាគារជាតិនៃកម្ពុជា
- លោក Robert Beerens ជំនាញការប្រចាំធនាគារជាតិនៃកម្ពុជា
- លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញាទាំងអស់ ជាទីមេត្រី!

ថ្ងៃនេះ ខ្ញុំមានក្តីសោមនស្សរីករាយជាអតិបរមា ដោយបានចូលរួមក្នុងសន្និបាតបូកសរុបលទ្ធផលការងារឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១៥ របស់យើងនាពេលនេះ ។ ជារៀងរាល់ឆ្នាំ យើងតែងតែប្រារព្ធពិធីនេះឡើង ដើម្បីផ្សព្វផ្សាយនិងអបអរសាទរសមិទ្ធផលការងាររបស់ធនាគារជាតិនៃកម្ពុជាយើង និងផ្តល់ឱកាសដល់មន្ត្រីបុគ្គលិកទាំងនៅស្នាក់ការកណ្តាលនិងសាខារាជធានី-ខេត្ត បានជួបប្រាស្រ័យទាក់ទង និងផ្លាស់ប្តូរបទពិសោធន៍ការងារគ្នា សំដៅពង្រឹងប្រសិទ្ធភាពការងារនិងរួមចំណែកអនុវត្តមុខងារភារកិច្ចរៀងៗខ្លួន ឱ្យសម្រេចបានជោគជ័យថ្មីៗបន្ថែមទៀត ។

ទន្ទឹមនឹងនេះ ខ្ញុំសូមថ្លែងកោតសរសើរចំពោះមន្ត្រីបុគ្គលិកគ្រប់ថ្នាក់ ដែលបានខិតខំប្រឹងប្រែងបំពេញមុខងារភារកិច្ចប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងសម្រេចបានសមិទ្ធផលជូនធនាគារជាតិនៃកម្ពុជា ជាពិសេសបានរួមចំណែកអភិវឌ្ឍប្រព័ន្ធធនាគារកាន់តែឱ្យរីកចម្រើន និងមានលក្ខណៈសមាហរណជាមួយប្រទេសក្នុងតំបន់និងពិភពលោកស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល ។



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

- គណៈអធិបតី

- លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!

ឆ្លៀតក្នុងឱកាសនេះ មុននឹងជម្រាបជូនពីសមិទ្ធផលការងាររបស់ធនាគារជាតិនៃកម្ពុជា ក្នុងឆមាសទី១ ឆ្នាំ២០១៥នេះ ខ្ញុំសូមជម្រាបជូនពីសារៈសំខាន់និងការវិវត្តប្រែប្រួលនៃតួនាទីធនាគារកណ្តាលនៅលើពិភពលោកបច្ចុប្បន្នថា តាមរយៈបទពិសោធន៍ដែលបានរៀនពីវិបត្តិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុធំៗ ដូចជា មហាវិបត្តិសេដ្ឋកិច្ចឆ្នាំ១៩២៩ វិបត្តិហិរញ្ញវត្ថុអាស៊ីឆ្នាំ១៩៩៧ និងវិបត្តិហិរញ្ញវត្ថុឆ្នាំ២០០៨ កន្លងមក បានធ្វើឱ្យប៉ះពាល់ដល់ជំនឿទុកចិត្តវិនិយោគិននិងអ្នកប្រើប្រាស់ បានធ្វើឱ្យប្រែប្រួលនិម្មាបនកម្មនិងអភិក្រមហិរញ្ញវត្ថុអន្តរជាតិ និងការប្រែប្រួលនៃតួនាទីធនាគារកណ្តាលក្នុងតំបន់និងពិភពលោកផងដែរ ដែលកាលពីមុនផ្តោតទៅលើការដឹកនាំគោលនយោបាយរូបិយវត្ថុដើម្បីរក្សាស្ថិរភាពថ្លៃ ហើយបច្ចុប្បន្ននេះកំពុងផ្តោតទៅលើស្ថិរភាពហិរញ្ញវត្ថុបន្ថែមទៀត ។ ការប្រែប្រួលថ្មីនេះក៏ជះឥទ្ធិពលដោយប្រយោលមកលើកម្ពុជាផងដែរ ដែលតម្រូវឱ្យអាជ្ញាធរទាំងអស់ ជាពិសេស ធនាគារជាតិនៃកម្ពុជាត្រូវពិចារណារៀបចំកសាងសមត្ថភាព និងក្របខ័ណ្ឌយន្តការការងារ ដើម្បីសម្របខ្លួនទៅតាមនិន្នាការថ្មីនេះដែរ ។

ចំពោះ**សភាពការណ៍ទូទៅនៃសេដ្ឋកិច្ចពិភពលោក តំបន់ និងសេដ្ឋកិច្ចកម្ពុជា** នៅឆមាសទី១ ឆ្នាំ២០១៥ ខ្ញុំសូមជម្រាបដោយសង្ខេបថា ៖

កំណើនសេដ្ឋកិច្ចសកលបន្តងើបឡើងក្នុងល្បឿនយឺត ដោយសារកំណើនសេដ្ឋកិច្ចប្រទេសធំៗមួយចំនួន ជាពិសេស សហរដ្ឋអាមេរិកនិងចិន បានបន្ថយល្បឿន ។ កំណើនសេដ្ឋកិច្ចសហរដ្ឋអាមេរិកបានថយចុះបន្តិច បណ្តាលមកពីភាពទន់ខ្សោយនៃការប្រើប្រាស់ក្នុងស្រុកនៅរដូវរងា ការថយចុះនៃការវិនិយោគលើវិស័យថាមពល និងការឡើងថ្លៃនៃប្រាក់ដុល្លារអាមេរិក ដែលបានធ្វើឱ្យប៉ះពាល់ដល់ការនាំចេញ ។ ចំណែកឯ សេដ្ឋកិច្ចតំបន់អឺរ៉ូមានភាពប្រសើរជាងមុនបន្តិច ដែលគាំទ្រដោយកំណើននៃការប្រើប្រាស់ឯកជននិងការនាំចេញដោយសារការធ្លាក់ចុះនៃថ្លៃប្រេងនិងប្រាក់អឺរ៉ូ ។ ដោយឡែក កំណើនសេដ្ឋកិច្ចចិនបានបន្តថយល្បឿនដល់កម្រិតទាបបំផុតក្នុងរយៈពេល ៦ឆ្នាំចុងក្រោយនេះ ដោយសារការថយចុះនៃវិស័យផលិតកម្មនិងការវិនិយោគលើអចលនទ្រព្យ ។ ទន្ទឹមនេះ កំណើនសេដ្ឋកិច្ចប្រទេសនៅតំបន់អាស៊ាន នៅតែនៅរក្សាភាពរឹងមាំដែលគាំទ្រដោយតម្រូវការក្នុងស្រុក ។

ចំពោះសេដ្ឋកិច្ចកម្ពុជាវិញ កំណើនសេដ្ឋកិច្ចបានបន្តរីកចម្រើនរឹងមាំ ដែលគាំទ្រដោយការបន្តងើបឡើងនៃសេដ្ឋកិច្ចសកល រួមនឹងការរក្សាបានស្ថិរភាពនយោបាយ សុខសន្តិភាព សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ លទ្ធផលនៃកម្មវិធីកំណែទម្រង់ និងការអនុវត្តនូវគោលនយោបាយសេដ្ឋកិច្ចចម្បងៗរបស់រាជរដ្ឋាភិបាលប្រកបដោយជោគជ័យ ។ ជាក់ស្តែង

កំណើនសេដ្ឋកិច្ចនៅឆ្នាំ២០១៥ នេះ ត្រូវបានរំពឹងថានឹងកើនឡើងក្នុងអត្រា ៦,៩% ដែលជាចម្បងជំរុញដោយវិស័យកាត់ដេរសម្លៀកបំពាក់ សំណង់និងអចលនទ្រព្យ ខណៈដែលវិស័យទេសចរណ៍និងកសិកម្មមានកំណើនយឺតជាងឆ្នាំមុន ។

ចំណែកឯ **លទ្ធផលការងារដែលធនាគារជាតិនៃកម្ពុជាសម្រេចបាន** ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១-២០២០ របស់រាជរដ្ឋាភិបាល មានដូចតទៅ ៖

**១/- វិស័យរូបិយវត្ថុ** : នៅក្នុងឆមាសទី១ នេះ តម្លៃប្រាក់រៀលបន្តមានស្ថិរភាពល្អប្រសើរ ដោយប្រែប្រួលក្នុងរង្វង់ ៤.០៥០ រៀលក្នុងមួយដុល្លារអាមេរិក ។ ស្ថិរភាពនេះទទួលបានតាមរយៈការបន្តអនុវត្តរបបអត្រាប្តូរប្រាក់អណ្តែតមានការគ្រប់គ្រង ដោយធ្វើអន្តរាគមន៍តាមការចាំបាច់ ជាពិសេស ដើម្បីឆ្លើយតបនឹងកំណើនតម្រូវការប្រាក់រៀល ដែលបានកើនឡើងឥតឈប់ឈរ ។ ចំណែកអតិផរណារូមឆ្នាំលើឆ្នាំ នាដំណាច់ឆមាសនេះ មានកម្រិតទាបប្រមាណតែ ១% ប៉ុណ្ណោះ ។ មកទល់បច្ចុប្បន្ន យើងបានគ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុ ប្រកបដោយភាពប្រុងប្រយ័ត្ន ក្នុងកម្រិតសមស្របទៅនឹងការរីកចម្រើននៃសេដ្ឋកិច្ចជាតិ តាមរយៈការផ្គត់ផ្គង់បរិមាណប្រាក់រៀលគ្រប់គ្រាន់តាមតម្រូវការទីផ្សារ និងការកំណត់អត្រាប្រាក់បម្រុងកាតព្វកិច្ចក្នុងកម្រិតដែលអាចរក្សាបរិមាណឥណទាននៅលើទីផ្សារ បានសមស្រប ។ ធនាគារជាតិនៃកម្ពុជាបានគរពូនទុនបម្រុងអន្តរជាតិជាលំដាប់ តាមរយៈការគ្រប់គ្រងយ៉ាងប្រុងប្រយ័ត្នបំផុត និងបានអភិវឌ្ឍក្របខ័ណ្ឌតាមដានវិភាគ និងព្យាករស្ថានភាពសន្ទនីយភាពនៅក្នុងសេដ្ឋកិច្ចប្រចាំថ្ងៃ សំដៅរក្សាកម្រិតសន្ទនីយភាពឱ្យបានគ្រប់គ្រាន់តាមតម្រូវការ ។

**២/- វិស័យធនាគារនិងហិរញ្ញវត្ថុ** : វិស័យនេះបន្តអភិវឌ្ឍរីកចម្រើនគួរឱ្យកត់សម្គាល់ទាំងវិសាលភាព និងទំហំប្រតិបត្តិការ ហើយបានដើរតួនាទីកាន់តែសំខាន់ក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។ ចំពោះផ្នែកវិសាលភាព គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានបន្តពង្រីកបណ្តាញប្រតិបត្តិការ តាមរយៈការបើកសាខានៅតាមរាជធានី-ខេត្ត ។ ចំនួនសាខាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានកើនឡើងជាង ៥ ដង ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ ។ ម៉ាស៊ីន ATM ដែលត្រូវបានបំពាក់ចាប់តាំងឆ្នាំ២០០៥ មក បានកើនឡើងរហូតដល់ជាង ១០០០ គ្រឿង នៅទូទាំងប្រទេស ។ សេវាហិរញ្ញវត្ថុត្រូវបានអភិវឌ្ឍជាបន្តបន្ទាប់ស្របតាមតម្រូវការទីផ្សារ ដើម្បីធ្វើឱ្យអតិថិជនមានលទ្ធភាពប្រើប្រាស់សេវាហិរញ្ញវត្ថុកាន់តែច្រើន ។ ចំពោះទំហំប្រតិបត្តិការវិញ ទាំងប្រាក់បញ្ញើ និងឥណទានរបស់ប្រព័ន្ធធនាគារ បានកើនឡើងយ៉ាងឆាប់រហ័ស ។ បច្ចុប្បន្ន អនុបាតប្រាក់បញ្ញើធៀបនឹងផ.ស.ស បានកើនឡើងដល់ ៥៤% អនុបាតឥណទានធៀបនឹងផ.ស.ស កើនដល់ ៥៥% ធៀបនឹង ១៥% និង ៩% នៅឆ្នាំ២០០៥ ។ ចំណែកឯ ឥណទានមិនដំណើរការ (NPL) មានកម្រិតទាបក្រោម ២,៧% និង ០,៧% ចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលបង្ហាញពីគុណភាពល្អនៃសម្ពាធឥណទានរបស់វិស័យធនាគារ ។